CARITAS CHRISTI URGET NOS

# អាទិត្យទី១៤នៃរដូវធម្មតា

# ព្រះសហគមន៍សន្តីម៉ារីញញឹម ចំការទៀង

# ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២១

## "អំណោយទានទាំង៧នៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺកម្លាំងដ៏ក្លាហានរបស់យើង"

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ជាពេលវេលាមួយដើម្បីឱ្យយើងនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ យើងអធិដ្ឋានពិសេសសម្រាប់បងប្អូនដែលកំពុងជាប់ចត្តាឡីស័ក។ ទូទាំងភូមិភាគភ្នំពេញ យើងមានបងប្អូនគ្រីស្តបរិស័ទមួយចំនួនដែលកំពុងជាប់ចត្តាឡីស័ក ដោយសារជាប់ពាក់ព័ន្ធដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩។ ជាពេលវេលាមួយ ដើម្បីអធិដ្ឋានសម្រាប់បងប្អូនយើងដែលកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩។ យើងបានឃើញប៉ុន្មានថ្ងៃកន្លងមក កូវីដ-១៩បានលូតលាស់ខ្លាំងរហូតដល់ជិតខ្ទង់ពាន់ជារៀងរាល់ថ្ងៃ។ គ្រីស្តបរិស័ទ ដែលភ្ជាប់នៅក្នុងសង្គមធម្មតាដូចបងប្អូនយើងទាំងអស់ក៏ត្រូវតែឆ្លងដែរ។ ដូច្នេះ ថ្ងៃនេះខ្ញុំអភិបូជានៅកន្លែងហ្នឹង កន្លែងនេះជាព្រះវិហារដែលយើងបានសាងសង់កាលពីសម័យកូវីដ-១៩ឆ្នាំមុន ដោយសារបានឃើញព្រះនាងម៉ារីបានជួយថែរក្សាការពារភូមិចំការទៀង។ ដូច្នេះ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ខ្ញុំក៏បានសាងសង់ព្រះវិហារតូចមួយ ដើម្បីឧទ្ទិសដល់ព្រះនាងម៉ារីដែលបានថែរក្សាការពារយើង។ ថ្ងៃនេះ ជាឱកាសមួយដើម្បីថ្វាយអភិបូជានៅមុខព្រះវិហារហ្នឹង ដើម្បីភ្ជាប់ជាមួយបងប្អូនទាំងអស់។

បងប្អូនដែលនៅសម្រាកព្យាបាលតាមមន្ទីរពេទ្យ បងប្អូនដែលនៅក្នុងមណ្ឌលធ្វើចត្តាឡីស័ក និងបងប្អូនដែលបានធ្វើចត្តាឡីស័កនៅតាមផ្ទះរៀងៗខ្លួន ដើម្បីឲ្យយើងយល់ថានៅក្នុងព្រះយេស៊ូគ្រីស្ត ពិតមែនយើងជាគ្រួសារតែមួយ ដែលស្រឡាញ់គ្នា ដែលលើកទឹកចិត្តគ្នា ដែលធ្វើដំណើរជាមួយគ្នា។ អម្បាញ់មិញ ខ្ញុំបានហែរចេញពីកូនព្រះវិហារនេះជាមួយរូបសន្តី អូឌីល សន្តី អូឌីល គឺជាសន្តីដែលបានទទួលមរណៈភាពនៅឆ្នាំ៧២០ គឺ១៣០០ឆ្នាំក្នុងស្រុកកំណើតរបស់ខ្ញុំនៅ

ប្រទេសបារាំង គាត់គឺជាសន្តីមួយរូបដ៏ល្បី ដែលបានជួយឱ្យមនុស្សប៉ុន្មានជំនាន់ពោរពេញដោយសេចក្តីសង្ឃឹម។

បងប្អូនជាទីស្រឡាញ់ ពីប៉ុន្មានសប្តាហ៍កន្លងមកខ្ញុំបានទេសនា អំពីសសរគ្រឹះនៃគុណធម៌ដែលយើងមាននៅក្នុងជំនឿរបស់យើង គឺទី១ជំនឿ ទី២សេចក្តីសង្ឃឹម ទី៣សេចក្តីស្រឡាញ់។ សន្តី អូឌីល បានប្រមូលទាំងជំនឿ ទាំងសេចក្តីសង្ឃឹម ទាំងសេចក្តីស្រឡាញ់នៅក្នុងជីវិតរបស់គាត់។ តាមពិតនៅពេលគាត់កើត ឪពុកម្តាយ ជាពិសេសឪពុកគាត់អន់ចិត្តមែនទែន ដោយសារតែគាត់ចង់បានកូនប្រុសដើម្បីបន្តត្រកូល។ ប៉ុន្តែ គាត់មានសុទ្ធតែកូនស្រី ហើយពៅគេក៏កូនស្រីទៀត ដូច្នេះគាត់ចង់សម្លាប់កូនស្រីពៅគាត់ចោលតែម្តង។ កូននេះកើតមកក៏ពិការភ្នែកទៀត ម្តាយក៏សង្គ្រោះកូនដោយសារជាទឹកចិត្តម្តាយ ហើយបានផ្ញើកូននេះនៅក្នុងអារាមបងស្រី ដើម្បីឱ្យបងស្រីជួយមើលកូនស្រីនេះ។ នៅពេលកូនស្រីនេះ មានអាយុ១២ឆ្នាំ គាត់បានទទួលអគ្គសញ្ញាជ្រមុជទឹក នៅពេលដែលគាត់ទទួលពិធីជ្រមុជទឹក ភ្នែករបស់គាត់បានភ្លឺ ហើយក៏មើលឃើញ ដូចជាព្រះជាម្ចាស់បានប្រទានជំនឿដល់គាត់ដើម្បីឱ្យគាត់មើលឃើញ គឺព្យាបាលជំងឺពីកំណើតរបស់គាត់។ ក្រោយមក គាត់បានមកដល់ស្រុកកំណើតរបស់គាត់ នៅពេលនោះឪពុករបស់គាត់បានស្វាគមន៍គាត់ និងគាត់សុខចិត្តលះបង់ចោលអ្វីៗទាំងអស់សម្រាប់ព្រះជាម្ចាស់។ គាត់បានប្រមូលយុវនារីមួយចំនួន ដើម្បីនៅជាមួយគាត់លើភ្នំមួយ ដើម្បីស្វាគមន៍ ជាពិសេសអ្នកជំងឺ អ្នកដែលគ្មានសេចក្តីសង្ឃឹម អ្នកដែលមានជំងឺឃ្លង់ ជនពិការ...។ គាត់ព្យាបាលពួកគេបានជាសះស្បើយយ៉ាងច្រើននៅក្នុងសេចក្តីស្រឡាញ់ និងនៅក្នុងសេចក្តីសង្ឃឹមរបស់គាត់ រហូតដល់គាត់ទទួលមរណៈភាព។

ថ្ងៃនេះ ដែលយើងគោរពសន្តី អូឌីល គម្រប់១៣០០ឆ្នាំ ជាសន្តីម្នាក់ដ៏ចាស់ដែលណែនាំឱ្យយើងចូលនៅក្នុងជំនឿរបស់យើងសារជាថ្មី។ ដូចយើងបានស្តាប់ថ្ងៃនេះ ក្នុងអត្ថបទទី២ យើងបានស្តាប់ថា "**ការប្រោសប្រណីរបស់យើងចំពោះអ្នកល្មមគ្រប់គ្រាន់ហើយ ដ្បិតឫទ្ធានុភាពរបស់យើងលិចចេញមកយ៉ាងខ្លាំងបំផុតនៅក្នុងមនុស្សទន់ខ្សោយ**"។ សន្តី អូឌីល គាត់គឺជាកូនក្មេងដែលពិការភ្នែក គាត់ជាកូនស្រីដែលឪពុកស្អប់បំផុត។ ប៉ុន្តែ នៅក្នុងភាពទន់ខ្សោយរបស់គាត់ គាត់បានទទួលព្រះអំណោយទានពីព្រះជាម្ចាស់។ ព្រះអំណោយទានរបស់ព្រះជាម្ចាស់ បានណែនាំឱ្យគាត់ទៅជាមនុស្សរឹងមាំ ពោរពេញដោយឫទ្ធានុភាពដែលមកពីព្រះជាម្ចាស់ផ្ទាល់។ ពិតមែនបងប្អូនជាទីស្រឡាញ់ យើងបានពិចារណាកន្លងមកអំពីជំនឿ អំពីសេចក្តីសង្ឃឹម អំពីសេចក្តីស្រឡាញ់ ថ្ងៃនេះយើងចង់ឆ្លើយនូវសំណួរដែលគេមានទៅព្រះយេស៊ូក្នុងគម្ពីរដំណឹងល្អដោយសារគេឆ្ងល់ **តើព្រះយេស៊ូមានឫទ្ធានុភាពមកពីណា? តើព្រះយេស៊ូមានបារមីមកពីណា? តើ**

**ព្រះយេស៊ូមានប្រាជ្ញាមកពីណា ដើម្បីទេសនាពីធម្មសាលាមួយទៅធម្មសាលាមួយ ដើម្បីណែនាំឱ្យអ្នកជំងឺជាសះស្បើយនៅគ្រប់ទីកន្លែងដែលព្រះយេស៊ូគង់នៅ?** ជាពិសេសនៅស្រុកកំណើត គេសួរ **តើគាត់ដឹងសេចក្ដីនេះមកពីណា? តើប្រាជ្ញាដែលគាត់បានទទួលនេះជាប្រាជ្ញាអ្វីទៅ?**

បងប្អូនជាទីស្រឡាញ់ យើងមានចម្លើយ ព្រះយេស៊ូបានទទួលប្រាជ្ញា ព្រះយេស៊ូបានដឹងសេចក្ដីទាំងនេះ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ ពីប៉ុន្មានថ្ងៃមុននៅភ្នំពេញថ្មី ខ្ញុំបានធ្វើពិធីព្រះពរទៅលើប្រេងពិសិដ្ឋ ដែលជាប្រេងដែលយើងប្រើសម្រាប់ធ្វើអគ្គសញ្ញាលាបថ្ងាស។ ឆ្នាំនេះដោយសារជំងឺកូវីដ-១៩ ខ្ញុំមិនដើរតាមកន្លែងនីមួយៗដូចខ្ញុំធ្វើជារៀងរាល់ឆ្នាំ។ ប៉ុន្តែ ជារៀងរាល់ឆ្នាំនៅពេលដែលខ្ញុំបានដើរតាមកន្លែងនីមួយៗដើម្បីធ្វើអគ្គសញ្ញាលាបថ្ងាស គឺព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់ ដែលយាងមកនៅក្នុងគ្រីស្តបរិស័ទរបស់យើង យុវជនយុវនារី បងប្អូនដែលបានទទួលពិធីជ្រមុជទឹក (ពន្លកថ្មី) ដើម្បីឱ្យបងប្អូនបានទទួលចំណេះដឹង ជំនឿ ប្រាជ្ញាមកពីព្រះជាម្ចាស់។

បងប្អូនជាទីស្រឡាញ់ ព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធមាន៧ គឺទី១ប្រាជ្ញា ទី២ការឈ្លាសវៃ ទី៣ការចេះផ្ដល់ដំបូន្មាន ទី៤ចិត្តអង់អាច ទី៥ចំណេះដឹង ទី៦ការគោរពប្រតិបត្តិគ្រប់ពេលវេលា និងទី៧ការគោរពកោតខ្លាចព្រះជាម្ចាស់។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឱ្យយើងមានយោបល់ល្អ ណែនាំឱ្យយើងចេះទទួលខុសត្រូវ ណែនាំឱ្យយើងមានប្រាជ្ញាឈ្លាសវៃ ណែនាំឱ្យយើងយល់អំពីសេចក្ដីពិត ណែនាំឱ្យយើងចេះគោរពកោតខ្លាចព្រះជាម្ចាស់នៅក្នុងសេចក្ដីស្រឡាញ់ ណែនាំឱ្យយើងធ្វើតាមព្រះវិញ្ញាណដ៏វិសុទ្ធ។ ទោះបី ខ្ញុំធ្វើអគ្គសញ្ញាលាបថ្ងាសមិនបាននៅឆ្នាំនេះ ខ្ញុំទៅតាមកន្លែងនីមួយៗមិនបាន ប៉ុន្តែខ្ញុំជឿថា នៅពេលហ្នឹងតាមរយៈអភិបូជាដែលយើងផ្សាយ តាមរយៈដែលបងប្អូនបានយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃ យើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធសារជាថ្មី។ យើងបានទទួលអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធសារជាថ្មី ដើម្បីទៅមុខនៅក្នុងជីវិតរបស់យើង។ យើងឃើញពីដើម ព្រះយេស៊ូបានយាងទៅភូមិនានា ហើយទ្រង់បង្រៀនអ្នកស្រុក សព្វថ្ងៃយើងទៅភូមិនានានៅជុំវិញមិនបាន។ ប៉ុន្តែ តាមរបៀបដែលយើងទំនាក់ទំនងពីចម្ងាយ (ZOOM) នៅក្នុងរបៀបថ្មីៗជាឱកាសមួយដើម្បីមានទំនាក់ទំនង។ រសៀលនេះ ខ្ញុំនឹងប្រជុំជាមួយសមាគមន៍សន្ត វ៉ាំងសង់ ជាពេលវេលាមួយដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមកនៅក្នុងពេលវេលាដ៏ពិបាកនេះ។ **តើក្រុមសន្ត វ៉ាំងសង់ អាចបង្ហាញធម៌មេត្តាករុណាដល់បងប្អូនឯទៀតៗដូចម្ដេច?** ដោយសារយើងមានរបៀបផ្សេងៗ យើងមិនជាប់ឃុំឃាំង យើងមិនជាប់នៅក្នុងផ្ទះ លើកលែងតែយើងធ្វើចត្តាឡីស័ក យើងអាចទៅសួរសុខទុក្ខបងប្អូនដែលកំពុងពិបាក។ ពី

ម្សិលមិញនៅក្នុងចំការទៀងយើងមានមេក្រុមកាយរិទ្ធិខ្លះៗ ដែលបានទៅសួរសុខទុក្ខចាស់ជរាដែលកំពុងរងទុក្ខលំបាកនៅក្នុងជីវិត យើងអាចធ្វើបាន។

ដូច្នេះ នៅក្នុងកម្លាំងដែលយើងបានទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធ ឱ្យយើងដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឱ្យយើងមានប្រាជ្ញាឈ្លាសវៃ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឱ្យយើងទទួលខុសត្រូវយ៉ាងខ្ពស់ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឱ្យយើងមានយោបល់ល្អ។ ជាពិសេស ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឱ្យយើងធ្វើតាមព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះជាការអស្ចារ្យ ព្រោះថាពេលយើងធ្វើតាមព្រះវិញ្ញាណដ៏វិសុទ្ធយើងមិនទៅជាមនុស្សដែលអាត្មានិយម ចង្អៀតចង្អល់ ចេះតែភ័យខ្លាច។ ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅគ្រប់ទីកន្លែង ព្រះយេស៊ូមិនដែលអស់សង្ឃឹមទេ។ ទោះបីនៅក្នុងភូមិកំណើត គេមិនទទួលស្គាល់ព្រះយេស៊ូក៏ដោយ ប៉ុន្តែព្រះអង្គទៅមុខព្រះអង្គបានចេញពីភូមិកំណើតដើម្បីទៅភូមិនានា ដើម្បីបន្តប្រកាសដំណឹងល្អឱ្យមនុស្សទាំងអស់អាចទទួលជីវិត ជីវិតដ៏បរិបូរណ៍តាមរយៈព្រះយេស៊ូ។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះដែលយើងនឹករលឹកដល់សន្តី អូឌីល ជាសន្តីម្នាក់ដែលណែនាំឱ្យយើងពោរពេញដោយជំនឿ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់។ យើងត្រូវតែថែរក្សាគុណធម៌ទាំង ៣ ដោយទូលអង្វរព្រះជាម្ចាស់សូមព្រះអង្គប្រទានព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធទាំង ៧មកសណ្ឋិតលើយើង ដើម្បីឱ្យយើងរួមគ្នាបន្តរស់នៅនៅក្នុងជំនឿ ដើម្បីឱ្យយើងរួមគ្នាបន្តធ្វើដំណើរនៅក្នុងសេចក្តីស្រឡាញ់ ដើម្បីឱ្យយើងរួមគ្នាបន្តថែរក្សាសេចក្តីសង្ឃឹម។ ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ម្តងហើយម្តងទៀត "**ការប្រោសប្រណីរបស់យើងចំពោះអ្នកល្មមគ្រប់គ្រាន់ហើយ**"។ នេះជាព្រះបន្ទូលដែលខ្ញុំបានជ្រើសរើស នៅពេលខ្ញុំបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៨ ចូល២៥ឆ្នាំនៅឆ្នាំនេះ។ នៅពេលនោះខ្ញុំបានរើសព្រះបន្ទូលនេះ ដោយដឹងថាការប្រោសប្រណីរបស់ព្រះជាម្ចាស់ល្មមគ្រប់គ្រាន់ហើយ យើងមិនត្រូវការអ្វីផ្សេងទេ។ ការប្រោសប្រណីរបស់ព្រះជាម្ចាស់ ជាព្រះអំណោយទានដែលយើងបានទទួលពីព្រះជាម្ចាស់ ជាកម្លាំងកាយកម្លាំងចិត្តរបស់យើង ជាសេចក្តីរីករាយរបស់យើង ជាសេចក្តីស្រឡាញ់ដែលជម្រុញយើង ដើម្បីឱ្យយើងកសាងព្រះសហគមន៍របស់យើង។

នៅពេលនេះយើងចូលក្នុងខែកក្កដា ជារៀងរាល់ឆ្នាំខែកក្កដាដូចជាខែដែលយើងកំពុងត្រៀមខ្លួនសម្រាប់សិស្សានុសិស្សប្រលងឌីប្លូម ប្រលងបាក់ឌុប។ ជារៀងរាល់ឆ្នាំ ខែនេះជាពេលវេលាដែលយើងត្រៀមខ្លួនដើម្បីរៀបចំកម្មវិធីបោះជំរំ ជាមួយយុវជនយុវនារី ជាមួយមេកាយរិទ្ធិ ជាមួយការ

ត្រាស់ហៅ។ ឆ្នាំនេះយើងមិនដឹងទេ ដោយសារកាលៈទេសៈនៃជំងឺកូវីដ-១៩ ណែនាំឱ្យយើងអាចត្រឹមតែសម្រុះសម្រួលពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែ យើងនឹកឃើញព្រះជាម្ចាស់គង់នៅជាមួយយើងថ្ងៃនេះ និងព្រះបន្ទូលរបស់ព្រះយេស៊ូបានកើតជារូបរាងថ្ងៃនេះ។ ដូច្នេះ ពីមួយថ្ងៃទៅមួយថ្ងៃ យើងយកចិត្តទុកដាក់ដោយនឹកឃើញគោលដៅដ៏ធំរបស់យើង គឺណែនាំឱ្យយើងមានសុភមង្គលដ៏ពិតប្រាកដ។ រួមជាមួយព្រះយេស៊ូ ដែលបានប្រកាសដំណឹងល្អពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ ដែលបានណែនាំឱ្យអ្នកជំងឺជាសះស្បើយយ៉ាងច្រើន។

សន្តី អូឌីល គាត់បានរកឃើញប្រភពនៃទឹកនៅលើភ្នំ រហូតដល់សព្វថ្ងៃ១៣០០ឆ្នាំមកហើយទឹកនេះនៅតែហូរចេញដដែល។ ខ្ញុំផ្ទាល់ ប៉ុន្មានដងប៉ុន្មានសារខ្ញុំបានទៅដល់កន្លែងហ្នឹងគ្រប់ពេលដែលខ្ញុំទៅប្រទេសបារាំង ដើម្បីសុំឱ្យព្រះជាម្ចាស់ប្រទានព្រះពរថែមទៀត ដើម្បីឱ្យតាមរយៈទឹកណែនាំឱ្យយើងទទួលជីវិតពីព្រះជាម្ចាស់ ឱ្យយើងមានកម្លាំងដើម្បីស្រឡាញ់ថែមទៀត ដើម្បីបម្រើថែមទៀត។

ថ្ងៃនេះ ខ្ញុំអធិដ្ឋានជាពិសេសសម្រាប់បងប្អូនទាំងអស់ដែលជាប់ចត្តាឡីស័ក បងប្អូនដែលកំពុងព្យាបាលជំងឺកូវីដ-១៩។ យើងផ្ញើកូនស្រី អូឌីល ដែលកំពុងពិបាកដោយសារជំងឺកូវីដ-១៩ នៅក្នុងដៃរបស់សន្តី អូឌីល។ សូមព្រះជាម្ចាស់ប្រទានព្រះពរដល់ព្រះសហគមន៍យើង ឱ្យយើងទាំងអស់គ្នាបន្តដើរឆ្ពោះទៅកាន់ជីវិត ជីវិតអស់កល្បជានិច្ច។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ